UNHCR



សុភាទន្សាយ

# ទន្សាយចាញ់ខ្យង




មជ្ឈមណ្ឌលពង្រីកការអប់រំ ខៅអ៊ីដាំង



ក្រោយពីស៊ីចេកឃាយអស់មួយល្អី
ទន្សាយរត់ចូលព្រៃ ធ្វើដំណើរផ្សងព្រេង
ទៅទៀត ។






ព្រះអាទិត្យបញ្ចេញកំដៅយ៉ាងខ្លាំង

ទន្សាយបែកញើសជោគខ្លួន

តែគេខំប្រឹងដើរទៅមុខជានិច្ច ។

ទន្សាយស្រេកទឹកជាខ្លាំង តែនៅតាមផ្លូវពុំប្រទះឃើញត្រពាំង បឹងបួរអ្វីសោះ ។ គេអង្គុយសំរាកព្រួយចិត្តជាខ្លាំង ។





ពេលនោះទន្សាយក្រឡេកឃើញកុកមួយហ្វូង។
គេគិតថា :  កុកជាសត្វស៊ីត្រី ត្រីជាសត្វរស់នៅ
ក្នុងទឹក ដូច្នេះកុកប្រាកដជាហើរទៅរកបឹង
ត្រពាំងដែលមានត្រី។ បើអញ្ចឹងអញត្រូវតែរត់
ទៅតាមហ្វូងកុកនេះ។



ទន្សាយឃើញត្រពាំងទឹកមួយពីចម្ងាយ ។ គេត្រេកអរ

ជាខ្លាំងខំរត់យ៉ាងលឿនទាល់តែដល់មាត់ត្រពាំងនោះ ។



ទន្សាយអោនចុះប្រុងនឹងផឹកទឹកអោយឆ្អែត

តាមអំណាចស្រេកខ្លាំង។



ពេលនោះសម្លេងមួយស្រែកពីក្នុងត្រពាំងថា៖

«អាណាមកលួចផឹកទឹកអញ?»



ទន្សាយភ្ញាក់នឹងសម្លេងនោះក៏ស្ទុះងើបឈរដៃទឹមចង្កេះស្រែកទៅវិញថា៖

«ចុះអាណានៅក្នុងត្រពាំង ម្ដេចក៏មិនចេញក្បាលមកឬក៏ជាខ្មោចលងទេដឹង»



ខ្យងឮដូច្នេះក៏ឡើងទៅលើស្លឹកឈូកបង្ហាញខ្លួនភ្លាមមួយរំពេច ហើយតបថា៖
«អញមិនមែនជាខ្មោចទេតែជាម្ចាស់ត្រពាំងនេះ។ ឯងផឹកទឹកឥតសុំអញ
អញមិនអោយឯងផឹកទេ»



ទន្សាយខឹងណាស់ស្រែកថា៖«យើ!អាខ្យងទេតើ អាណាចាត់តាំងអោយអាអត់ជើងនេះធ្វើជាម្ចាស់ត្រពាំង? តាំងពីដូនតាមកត្រពាំងនេះគ្មានម្ចាស់ទេ!

- នែអាត្រចៀកវែង! ត្រពាំងនេះជាលំនៅរបស់អញតកូនតចៅ ដូច្នេះត្រពាំងនេះជារបស់អញ អាឯងត្រូវតែថយចេញពីទីនេះអោយឆាប់ទៅ (ខ្យងឆ្លើយ) ។
- នែ! អាអត់ជើងអណ្ដែតតាមខ្យល់ ទំរាំបានដល់ស្លឹកឈូកភ័យស្លន់ស្លោ!
- នែ! អាត្រចៀកវែង ថ្វីត្បិតតែអាឯងមានជើងដល់ទៅបួន តែអាឯងមិនមែនរត់ឈ្នះអញទេ ។
- អើ! អាអត់ជើង បើគ្រាន់បើ អាឯងហ៊ានរត់ប្រណាំងនឹងអញឬទេ?
- ចុះអញមានទៅខ្លាចអាឯងអី! តែមុននឹងភ្នាល់ត្រូវធ្វើខសន្យាសិន ។




ពាក្យខសន្យា
- បើខ្យងចាញ់ ខ្យងទាំងអស់នឹងឈប់
រស់នៅក្នុងទឹកត្រពាំងបឹងបួរ
- បើទន្សាយចាញ់ ទន្សាយទាំងអស់នឹង
ឈប់ផឹកទឹកត្រពាំងបឹងបួរ
ហត្ថលេខា
ហត្ថលេខា
PHAN

ខ្យងមានគ្នាច្រើន គេបណ្តាត់គ្នាជុំវិញត្រពាំង

ហើយប្រាប់គ្នីគ្នាថា បើទន្សាយហៅ អោយខ្យងនៅ

ខាងមុខ ឆ្លើយជានិច្ច ។

នាទីប្រណាំងមកដល់ហើយទន្សាយរត់លើគោក

ខ្យងរត់ក្នុងទឹក ។ គេយកជុំវិញត្រពាំងជាទីប្រណាំង ។



រត់បានមួយជុំត្រពាំង ទន្សាយស្រែកហៅខ្យង «អើ! អាខ្យង» ។ ខ្យងនៅខាងមុខឆ្លើយ «ថា គូក!» ។ ទន្សាយភ្លាត់មាត់ថា «ប៉ៃ! អានេះរត់លឿនណាស៊ុី!»រួចទន្សាយក៏ខំបន្ថែមល្បឿនមួយកំរិតទៀត ។





ពេលណាទន្សាយស្រែកហៅ ខ្យងនៅខាងមុខឆ្លើយថា «គូក»ជានិច្ច ។ ទន្សាយភ័យណាស់ខ្លាចចាញ់ខ្យង ក៏ខំប្រឹងរត់លឿនឡើងៗ ទាល់តែដួលព្រួសនៅមួយកន្លែង ។

បាត់មាត់ទន្សាយ ខ្យងឡើងទំលើផ្កាឈូករួចដកកយ៉ាងវែងសួរទៅទន្សាយថាៈ

«យ៉ាងម៉េចទៅហើយ អាទន្សាយ?»ទន្សាយឆ្លើយទាំងដង្ហក់ថាៈ

«ខ្ញុំចាញ់បងខ្យងឯងហើយ»



ចាប់តាំងពីថ្ងៃនោះមក ទន្សាយលែងហ៊ានផឹក

ទឹកត្រពាំងបឹងបួរ ។ គេផឹកទឹកសន្សើមជំនួសវិញ ។



9789996317163

គណៈកម្មការនាយក
- លោក សុក ប៊ុនហេង
- លោក សោម ឆេង
- លោក តូ ហូ

អ្នកនិពន្ធ
អ្នកស្រី ឆេង សុភ័ព្ទ





គណៈកម្មការវិចិត្រករ
- លោក អ៊ិន យី
- លោក តឹង គិមនិត
- លោក ឈុំ សំជិត
- លោក ដួង កាយ
- លោក ស្បោង ផាន់
- លោក ប៉ា ស្រ៊ុន
- លោក សិរិទ្ធ សុខុម

គណៈកម្មការពិនិត្យ
-លោក ឡុង ឈុំ
-លោក ហៃ លី
-អ្នកស្រី ពឹង គិមសួរ
- អ្នកស្រី ធូ ថេន
- លោក គង់ ហ៊ល
- លោក ចក់ អ៊ុត

This original edition was produced by the Education Development Center,
Khao I Dang, and was printed in May 1980 by Caring for Young Refugees.

This book was reprinted by Caring for Young Khmer with the financial assistance of Ms. Nobuko ASAI

បោះពុម្ពឡើងវិញដោយ : អង្គការគាំពារកុមារខ្មែរ (CYK)
នៅភ្នំពេញ ខែកក្កដា ឆ្នាំ២០១០
មូលនិធិ : លោកស្រី អាសាយ ណូប៊ុកុ
ចំនួន : ៣០០ក្បាល
លេខ : CYK N10028
រោងពុម្ព : JSRC Printing House

増刷：特定非営利活動法人　幼い難民を考える会
2010 年 7 月　プノンペン
協力：浅井　信子
部数：300 冊
番号：CYK N10028
印刷所：JSRC Printing House